Creative Green Design Co., Ltd
Social-Environmental Researchs
Quality Researchers

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ជំពូកទីជ៖ ផែនការគ្រប់គ្រងបរិស្ថាន

Draft

ជំពូកទី៨៖ ផែនការគ្រប់គ្រងបរិស្ថាន

៨.១ សេចក្តីផ្តើម

ផែនការគ្រប់គ្រងបរិស្ថាន (ផ.គ.ប) គឺជាផែនការមួយដែលត្រូវរៀបចំឡើងដោយម្ចាស់គម្រោង ស្ថិតក្រោមកិច្ចសហការចុះត្រួតពិនិត្យពីស្ថាប័នជំនាញចម្រុះ ដែលពាក់ព័ន្ធដើម្បីធ្វើការត្រួតពិនិត្យនៅក្នុងដំណាក់កាលសាងសង់ ដំណាក់កាលប្រតិបត្តិ និងការថែទាំ ដំណាំក្នុងគោលដៅកាត់បន្ថយហេតុប៉ះពាល់ដែលអាចនឹងកើតមាន។ ផែនការគ្រប់គ្រងបរិស្ថានធ្វើឡើង ដើម្បីធ្វើការតាមដានទៅលើការអនុវត្ត វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលបានលើកឡើងនៅក្នុងជំពូកទី៧ ដើម្បីឱ្យប្រាកដថា រាល់វិធានការទាំងអស់ ដែលបានលើក ឡើងត្រូវបានអនុវត្តដោយម្ចាស់គម្រោង នៅរាល់ដំណាក់កាលដែលគេរកឃើញថាមានហេតុប៉ះពាល់បណ្តាលមកពីគម្រោងវិនិយោគនេះ។ ម្យ៉ាងទៀត ផែនការគ្រប់គ្រងបរិស្ថាន ត្រូវគូសបញ្ជាក់ អំពីកិច្ចការពារបរិស្ថាន និងវិធានការនានា ដែលត្រូវអនុវត្តនៅពេលប្រតិបត្តិគម្រោងដោយគោរពទៅតាមច្បាប់ អនុក្រឹត្យ និងបទបញ្ញត្តិនានា ក្នុងគោលបំណង កាត់បន្ថយរាល់ហេតុប៉ះពាល់ជា អវិជ្ជមានដែលអាចកើតមាន។ បន្ថែមពីនេះទៀត ត្រូវមានការបង្កើនចំណេះដឹងអំពីកិច្ចការពារ បរិស្ថាន-សង្គម តាមរយៈការបណ្តុះបណ្តាលដល់បុគ្គលិកដែលពាក់ព័ន្ធជាមួយនឹងសកម្មភាពនៃ គម្រោងតាមដំណាក់កាលនីមួយៗ។

៨.២ ការរៀបចំស្ថាប័ន

ក្រុមហ៊ុនវិនិយោគធ្វើការអង្កេតតាមដាន និងត្រួតពិនិត្យជាប្រចាំគ្រប់ដំណាក់កាលរបស់ គម្រោងដែលស្ថិតនៅក្រោមការត្រួតពិនិត្យ និងតាមដានពីក្រុមការងារអន្តរក្រសួង ទៅតាមពេល វេលាដែលបានកំណត់ក្នុងតារាងផែនការសំរាប់ការចុះត្រួតពិនិត្យ។ ផ្ទុយទៅវិញ ប្រសិនមានការ ប្រែប្រួលខ្លាំងចំពោះស្ថានភាពបរិស្ថានក្នុងតំបន់គម្រោងស្ថិតក្នុងពេលណាមួយ ដែលមិនទាន់ដល់ពេលដែលអន្តរក្រសួងដែលពាក់ព័ន្ធចុះទៅត្រួតពិនិត្យ ខាងក្រុមហ៊ុនត្រូវធ្វើរបាយការណ៍ជាបន្ទាន់ ទៅឱ្យស្ថាប័នជំនាញទាំងនោះ ដើម្បីធ្វើការចុះត្រួតពិនិត្យ និងចាត់វិធានការទប់ស្កាត់ឱ្យបានទាន់ ពេលវេលា។

ដូចនេះ ដើម្បីកំណត់និងធ្វើការកាត់បន្ថយនូវហេតុប៉ះពាល់បរិស្ថាន ដែលអាចកើតមាន ដោយសារសកម្មភាពគម្រោងបង្កប់ខ្សែអុកទិចក្រោមសមុទ្រ ដែលតម្រូវឱ្យម្ចាស់គម្រោងរៀបចំផែនការគ្រប់គ្រងបរិស្ថានដូចខាងក្រោម៖

Draft

៨.២.១ ស្ថាប័នទទួលខុសត្រូវ

ក. ម្ចាស់គម្រោង

នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ត្រូវមានការ បញ្ជាក់ឱ្យច្បាស់លាស់ និងចាត់វិធានការកាត់បន្ថយនូវហេតុប៉ះពាល់ដោយសារសកម្មភាពគម្រោង នេះ តម្រូវឱ្យម្ចាស់ក្រុមហ៊ុនវិនិយោគ និងអ្នកអនុវត្តការងារ មានទំនួលខុសត្រូវទាំងស្រុងលើគ្រប់សកម្មភាពមានក្នុងដំណាក់កាលសាងសង់ និងដំណាក់កាលប្រតិបត្តិគម្រោង ដែលនឹងបង្កគ្រោះថ្នាក់ដល់ធនធានដែលមានស្រាប់ដូចជា ធនធានបរិស្ថានរូបសាស្ត្រ ធនធានជីវៈសាស្ត្រ និងសង្គម-សេដ្ឋកិច្ច។ ដូចនេះ ការត្រួតពិនិត្យ និងការតាមដាននឹងធ្វើឡើង ជាប្រចាំសប្តាហ៍ឬប្រចាំខែក្នុង តំបន់គម្រោងនៅក្នុងដំណាក់កាលនីមួយៗនៃគម្រោង។

ក្នុងនោះ ផែនការគ្រប់គ្រងបរិស្ថាន ក៏តម្រូវឱ្យអ្នកគ្រប់គ្រងការដ្ឋាន និងអ្នកជំនាញឯកទេសមានការត្រួតពិនិត្យសកម្មភាពបុគ្គលិក កម្មករ និងធ្វើសកម្មភាពក្នុងលក្ខខ័ណ្ឌកិច្ចសន្យា ដើម្បីការពារ និងកាត់បន្ថយនូវការខូចខាតទៅលើបរិស្ថាន និងសង្គម ដោយមានកត្តាចំនួន០២គឺ៖

- ❖ អ្នកគ្រប់គ្រង និងប្រធានការដ្ឋាន ជាអ្នកទទួលខុសត្រូវចុងក្រោយនៃបញ្ហាបរិស្ថានសម្រាប់ការដឹកនាំ និងសកម្មភាពគ្រប់គ្រងប្រចាំថ្ងៃ។ ការធ្វើដូចនេះមានសារៈសំខាន់សម្រាប់ការអនុញ្ញាតឱ្យអ្នកត្រួតពិនិត្យបរិស្ថានមានវត្តមានជាអចិន្ត្រៃយ៍នៅនឹងទីតាំង ហើយអ្នកទទួលខុសត្រូវជាអ្នកកំណត់ពេលវេលាក្នុងការត្រួតពិនិត្យគម្រោងប្រចាំថ្ងៃ។
- ❖ ចំពោះការត្រួតពិនិត្យ និងតាមដានបុគ្គលិក-កម្មករ ត្រូវមានបទពិសោធន៍គ្រប់គ្រាន់អំពីការគ្រប់គ្រងបរិស្ថាន។ អ្នកត្រួតពិនិត្យបរិស្ថាននឹងចូលរួមជារៀងរាល់សប្តាហ៍នៅកន្លែងសាងសង់ និងការដ្ឋានដាំដុះជាមួយ នឹងបុគ្គលិកជំនាញនិងអ្នកគ្រប់គ្រងការដ្ឋានហើយនឹងផ្តល់ព័ត៌មានដែលកើតឡើងនៅរយៈពេលខ្លីខាងមុខនៅទីនោះ។ អ្នកត្រួតពិនិត្យបរិស្ថាននឹងរៀបចំរបាយការប្រចាំខែ ប្រចាំត្រីមាស និងឆមាសសម្រាប់ដាក់ជូនទៅភ្នាក់ងារពាក់ព័ន្ធ ដូចជាក្រសួងបរិស្ថានជាដើម។

ខ. អ្នកម៉ៅការសាងសង់

ក្រុមហ៊ុនដែលម៉ៅការសម្រាប់សាងសង់សម្រាប់គម្រោងបង្កប់ខ្សែកាប្ល៊ីអុបទិចនេះ គឺក្រុមហ៊ុន Huawei Marine Network ដែលជាក្រុមហ៊ុនមានជំនាញ និងបទពិសោធន៍ក្នុងការបង្កប់ខ្សែកាប្ល៊ីដ៏ល្បីនៅលើសកលលោក។ អ្នកម៉ៅការសាងសង់ (ក្រុមហ៊ុន Huawei Marine Network) ត្រូវបង្ហាញនូវ រាល់ឯកសារទាំងឡាយណាដែលបានស្នើឡើងស្តីពី គោលការណ៍ណែនាំផ្នែកបរិស្ថានអោយបានច្បាស់លាស់

និងធ្វើការការរៀបរាប់លម្អិតអំពីការងារទទួលខុសត្រូវសម្រាប់កិច្ចការពារបរិស្ថាននៅក្នុងអង្គភាពអ្នកម៉ៅការ ដែលគឺជាកត្តាសំខាន់សម្រាប់កិច្ចការត្រួតពិនិត្យបរិស្ថានអោយបានល្អ។ ដូច្នេះ វាជាកត្តាចំបាច់ណាស់តម្រូវអោយអ្នកម៉ៅការផ្តល់អោយនូវគម្រោងការគ្រប់គ្រងបរិស្ថាន។

៨.២.២ ស្ថាប័នត្រួតពិនិត្យ

ក. ក្រុមការងារថ្នាក់ជាតិ

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនៃគម្រោងវិនិយោគបង្កប់ខ្សែកាប្ល៊ីអុបទិចក្រោមបាតសមុទ្រ គម្រូវឱ្យមានការចូលរួមពិគ្រោះយោបល់ពីហេតុប៉ះពាល់ទាំងឡាយណា ដែលគម្រោងនេះ បានបង្កឡើង។ សមាសភាពនៃក្រុមការងារថ្នាក់ជាតិ ដែលចូលរួមត្រួតពិនិត្យ លើគម្រោងវិនិយោគនេះមានដូចខាងក្រោម៖

- ក្រសួងបរិស្ថាន
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងរ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងធនធានទឹក និងឧតុនិយម
- គណៈកម្មការសន្តិសុខលំហារសមុទ្រ

ខ. ក្រុមការងារថ្នាក់ក្រោមជាតិ

ក្រសួងបរិស្ថានមានសិទ្ធិចង្អុលបង្ហាញ សមាជិកនៃគណៈកម្មការដើម្បីចុះពិនិត្យទីតាំងជាក់ស្តែងជាបន្ទាន់ ក្នុងករណីមានការប្រែប្រួលបរិស្ថានខ្លាំងក្នុងគម្រោងវិនិយោគ ដើម្បីជួយរកវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន និងដើម្បីចាត់វិធានការទប់ស្កាត់នូវហានិភ័យដែលអាចនឹងកើតមានឡើង។

ជាទូទៅនាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន នៃអគ្គនាយកដ្ឋានគាំពារបរិស្ថានរបស់ក្រសួងបរិស្ថាន តែងតែចុះអង្កេតតាមដានពីសកម្មភាពគម្រោងរៀងរាល់៣ខែ ឬ៦ខែ ឬ១ឆ្នាំម្តង។ ក្នុងករណីសកម្មភាពគម្រោង មានការប៉ះពាល់អវិជ្ជមានខ្លាំងដល់បរិស្ថាន សង្គម និងសេដ្ឋកិច្ច ដែលក្រសួងបរិស្ថានអាចចុះត្រួតពិនិត្យនៅគ្រប់ពេលដើម្បីចាត់វិធានការជាបន្ទាន់។

Draft

Draft

តួនាទី និងកាតព្វកិច្ចក្នុងការត្រួតពិនិត្យ និងសម្របសម្រួលរាល់បញ្ហាដែល កើតមានឡើងនៅក្នុងតំបន់គម្រោងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ សមាសភាពនៃអ្នកត្រួតពិនិត្យ របស់ស្ថាប័នថ្នាក់ក្រោមជាតិមានដូចខាងក្រោម៖

- សាលាខេត្តព្រះសីហនុ
- សាលាក្រុងព្រះសីហនុ
- មន្ទីរបរិស្ថានខេត្តព្រះសីហនុ
- មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តព្រះសីហនុ
- មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រះសីហនុ
- មន្ទីរទេសចរណ៍ខេត្តព្រះសីហនុ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ
- សង្កាត់លេខ៤
- ភូមិពាក់ព័ន្ធ

៨.២.៣ ការធ្វើរបាយការណ៍

អ្នកត្រួតពិនិត្យបរិស្ថានចូលរួម នៅក្នុងទីតាំងគម្រោងជាមួយនឹងបុគ្គលិក ហើយនឹងផ្តល់ព័ត៌មានអ្វីដែលកើតឡើងនៅរយៈពេលខ្លីខាងមុខទីនោះ។ អ្នកត្រួតពិនិត្យបរិស្ថាន និងរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស និងឆមាសសម្រាប់ដាក់ជូនទៅភ្នាក់ងារពាក់ព័ន្ធដូចជាក្រសួងបរិស្ថានជាដើម។

តារាង៨.១៖ ផែនការគ្រប់គ្រងបរិស្ថាន និងការទទួលខុសត្រូវនៃគម្រោងវិនិយោគនេះ

សកម្មភាព	ការអនុវត្តន៍ និងការទទួលខុសត្រូវ
ការប្រមូលទិន្នន័យ	ម្ចាស់គម្រោង និងទីប្រឹក្សាគម្រោង
ការវិភាគទិន្នន័យ	ម្ចាស់គម្រោង និងទីប្រឹក្សាគម្រោង
ការធ្វើរបាយការណ៍មាន: - ប្រចាំខែ - ប្រចាំត្រីមាស - ប្រចាំឆ្នាំ	ការិយាល័យគ្រប់គ្រងនិងទីប្រឹក្សាគម្រោង
ការទទួលរបាយការណ៍: - ជាប្រចាំឆមាស	- ម្ចាស់គម្រោង - ក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានខេត្តព្រះសីហនុ

	- មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តព្រះសីហនុ - សាលាខេត្តព្រះសីហនុ - សង្កាត់ និងមេភូមិដែលពាក់ព័ន្ធ
ការផ្តល់យោបល់/ប្រឹក្សា	ក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្តព្រះសីហនុ និងស្ថាប័នពាក់ព័ន្ធនានា ទាក់ទងនឹងគ្រប់សកម្មភាពនៃគម្រោង។

៨.៣ ការសង្ខេបពីហេតុប៉ះពាល់អវិជ្ជមានសំខាន់ៗ និងវិធានការការពារបរិស្ថាន

នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ទាមទារឱ្យក្រុមហ៊ុនលើកយកនូវរាល់ចំនុចហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន និងមានវិធានការការពារបរិស្ថានជាលក្ខណៈសង្ខេបបំផុត។ ទោះបីជាយ៉ាងណា ក្រុមហ៊ុនត្រូវតែអនុវត្តឱ្យបាន គ្រប់រាល់ការលើកឡើងពីហេតុប៉ះពាល់បរិស្ថាន និងសង្គម-សេដ្ឋកិច្ច និងវិធានការកាត់បន្ថយដែលមានរៀបរាប់ក្នុងជំពូកទី៧ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយដោយធ្វើយ៉ាងណាឱ្យហេតុប៉ះពាល់នេះ ស្ថិតនៅក្នុងកម្រិតអប្បរមា។

៨.៣.១ ហេតុប៉ះពាល់អវិជ្ជមានសំខាន់ៗ

ក. ដំណាក់កាលរចនាគម្រោង

នៅដំណាក់កាលនេះអាចធ្វើឲ្យមានការប៉ះពាល់ដល់ តំបន់ផ្ការថ្ម តំបន់នេសាទ ផ្លូវនាវាចរណ៍ តំបន់រុករកប្រេង និងឧស្ម័ន តំបន់ឆ្នេរ និងផ្លូវស្របតំបន់ឆ្នេរ តាមរយៈសកម្មភាពមួយចំនួនដូចជាការសិក្សាពីជម្រើសនៃការបង្កប់ខ្សែកាប្លឹ ការសិក្សាអំពីធនធានបរិស្ថានដែលមានស្រាប់មុននឹងធ្វើការបង្កប់ខ្សែកាប្លឹ។

ខ. ដំណាក់កាលសាងសង់

ការត្រួតពិនិត្យក្នុងកំឡុងពេលសាងសង់ ក្រុមហ៊ុនត្រូវអនុវត្តចំពោះហេតុប៉ះពាល់បរិស្ថានចម្បងៗទៅលើធនធានរូបសាស្ត្រ ជីវសាស្ត្រ និងសេដ្ឋកិច្ច-សង្គមនៅក្នុងតំបន់នោះ ដែលអាចបង្កឡើងដោយសារសកម្មភាពនានានៅក្នុងដំណាក់កាលនេះ។

សកម្មភាពការឈូសឆាយ ការជីកបង្កប់ខ្សែ និងសាងសង់របស់គម្រោង អាចនឹងធ្វើឱ្យប៉ះពាល់ដល់សណ្ឋានដីបាតសមុទ្រនិងសណ្ឋាននៅលើគោក ហើយក៏អាចបណ្តាលឱ្យមានការហូរច្រោះដីនៅតាមគន្លងខ្សែ និងតាមតំបន់ឆ្នេរផងដែរ។ លើសពីនេះ វាធ្វើឱ្យមានការស្ទះចរាចរណ៍ ការរំខានដោយសម្លេងនិងរំញ័រ ដល់ប្រជាជនតិចតួច។

ការគ្រប់គ្រងសំណល់រឹង និងរាវមិនត្រឹមត្រូវក៏បណ្តាលឱ្យប៉ះពាល់ដល់គុណភាពទឹក គុណភាពដី គុណភាពខ្យល់ ធនធានជីវៈចម្រុះក្នុងសមុទ្រ សុខភាពសាធារណៈ និងទេសចរណ៍ នៅតំបន់ជុំវិញគម្រោងផងដែរ។

គ. ដំណាក់កាលប្រតិបត្តិគម្រោង

ផលប៉ះពាល់អវិជ្ជមានដែលនឹងអាចកើតចេញពីដំណាក់កាលនេះ គឺអាចនឹងមានផលប៉ះពាល់ដោយមេកានិក និងការកើនឡើងកម្តៅដែលកាយចេញពីខ្សែកាប្ល៊ី។

ឃ. ដំណាក់កាលបញ្ចប់គម្រោង

ក្នុងដំណាក់កាលនេះ នឹងអាចបណ្តាលឱ្យមានផលប៉ះពាល់ដល់មុខរបរការងារ ប្រាក់ចំណូលរបស់បុគ្គលិកដែលបម្រើការដោយគម្រោង និងធ្វើឱ្យប៉ះពាល់ដល់បរិស្ថានតិចតួចនៅពេលក្រុមហ៊ុនរក្សាទុកខ្សែកាប្ល៊ីចោលក្រោមបាតសមុទ្រ។

៨.៣.២ វិធានការការពារបរិស្ថាន

ក្រោយពីកំណត់នូវហេតុប៉ះពាល់ដែលកើតឡើងដោយសារសកម្មភាពនៃគម្រោង យើងនឹង មានវិធានការការពារបរិស្ថាន ដែលធ្វើឡើងនៅគ្រប់ដំណាក់កាលនៃគម្រោង ទើបក្រុមហ៊ុននឹង រៀបចំកំណត់នូវវិធានការមួយចំនួនដើម្បីធ្វើការទប់ស្កាត់ និងមានវិធានការកាត់បន្ថយរាល់ហេតុប៉ះ ពាល់អវិជ្ជមានដែលកើតមានឡើងនូវរាល់សកម្មភាពរបស់គម្រោង និងដើម្បីធានាការគ្រប់គ្រងធនធានបរិស្ថានដែលមានស្រាប់ក្នុងតំបន់គម្រោងធានាឱ្យមានប្រសិទ្ធភាពស្របទៅតាមលក្ខណៈបច្ចេកទេសនិងបទដ្ឋានបរិស្ថាន។ ដូចនេះក្រុមហ៊ុន នឹងធានាឱ្យបាននូវការគ្រប់គ្រងប្រកបដោយស្ថេរភាពគ្រប់ដំណាក់ទាំងអស់នៃគម្រោងគឺ៖

- រៀបចំផ្នែក ឬក្រុមទទួលខុសត្រូវសម្រាប់អនុវត្តផែនការគ្រប់គ្រងផែនការបរិស្ថាន។
- បំពាក់ឧបករណ៍ការពារសុខភាព/សុវត្ថិភាព និងគ្រឿងចក្រទំនើបៗតាមបែបបច្ចេកទេស នៅក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិគម្រោង។
- ការពារ និងបង្ការជំងឺរាតត្បាតផ្សេងៗ ជាពិសេសរៀបចំឲ្យមានបន្ទប់ព្យាបាលជម្ងឺ និងមានគ្រូពេទ្យប្រចាំការនៅពេលមានបញ្ហា។
- គ្រប់គ្រងសំណល់រឹង-រាវ និងសំណល់សារធាតុពុលឱ្យបានល្អ។
- ធ្វើការអភិរក្សធនធានជីវចម្រុះដែលធ្លាប់មាននៅក្នុងតំបន់គម្រោង។

- ធ្វើការផ្សព្វផ្សាយ និងអប់រំណែនាំវិធីសាស្ត្រការពារសុខភាព អនាម័យ សុវត្ថិភាពការងារ ជៀសវាងមានគ្រោះថ្នាក់ជាយថាហេតុ។
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជំនាញក្នុងការត្រួតពិនិត្យមើលទីតាំងគម្រោង និងទទួលយកនូវអនុសាសន៍ ដើម្បីធ្វើការកែប្រែបច្ចេកទេសណាមួយដែលអ្នកជំនាញបានតម្រូវ។
- មានការរៀបចំនូវរបាយការណ៍ជាប្រចាំនូវរាល់សកម្មភាពផ្សេងៗដែលកើតឡើងរាល់គ្រប់ដំណាក់កាលទាំងអស់ ដើម្បីងាយស្រួលចាត់វិធានការទប់ស្កាត់ទាន់ពេលវេលា។
- ក្រុមហ៊ុនត្រូវត្រៀមថវិកាមួយផ្នែកតូច ដែលបានពីប្រាក់ចំណូលសម្រាប់មូលនិធិបរិស្ថាននិងសង្គម ដោយមូលនិធិបរិស្ថានត្រូវចំណាយ ដើម្បីប្រើប្រាស់សម្រាប់ស្តារបរិស្ថានឡើងវិញ ដូចជាការដាំដើមឈើឡើងវិញ អភិរក្សជលផល និងត្រួតពិនិត្យគុណភាពបរិស្ថាន។ ចំណែកមូលនិធិសង្គម ក្រុមហ៊ុនត្រៀមថវិកាផងដែរ ដើម្បីប្រើប្រាស់ក្នុងការបណ្តុះបណ្តាល ជំនាញផ្សេងៗ កសាងហេដ្ឋារចនាសម្ព័ន្ធ និងផ្តល់ជាប្រាក់កម្ចីឥតការប្រាក់។

៨.៤ កម្មវិធីបណ្តុះបណ្តាល

កម្មវិធីបណ្តុះបណ្តាល ជាកត្តាសំខាន់មួយនៅក្នុងផែនការគ្រប់គ្រងបរិស្ថានផងដែរ ដែលម្ចាស់គម្រោងត្រូវយកចិត្តទុកដាក់ដើម្បីអនុវត្តផែនការមេរបស់គម្រោងឱ្យបានជោគជ័យ។ ដើម្បីធ្វើឱ្យគម្រោងនេះមានស្ថេរភាពចាំបាច់ត្រូវមានធនធានមនុស្ស ដែលមានសមត្ថភាពគ្រប់គ្រាន់សម្រាប់បំពេញការងារឱ្យបានរីកចម្រើន សុក្រឹត្ស ត្រឹមត្រូវទាំងការងារបច្ចេកទេស និងការងារបរិស្ថាន។ ការបណ្តុះបណ្តាលទាំងនេះ ក្រុមហ៊ុននឹងទទួលបន្ទុកលើការចំណាយទាំងស្រុង។ ដូចនេះ ម្ចាស់គម្រោងនឹងរៀបចំឱ្យមានវគ្គអប់រំបំប៉ន់មន្ថែមដល់បុគ្គលិក-កម្មករ រួមមានដូចខាងក្រោម:

- ផ្តល់ចំណេះដឹងបច្ចេកទេសសំរាប់ប្រើប្មបញ្ជាគ្រឿងចក្រម៉ាស៊ីនគ្រប់ប្រភេទក្នុងដំណើរការគម្រោង។
- បំពាក់បំប៉ន និងផ្សព្វផ្សាយពីជំនាញបច្ចេកទេស ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗដែលពាក់ព័ន្ធ។
- បណ្តុះបណ្តាលដល់កម្មករឲ្យបំពាក់ឧបករណ៍ការពារសុខភាពពេលកំពុងធ្វើការ។
- អប់រំកម្មករពីអត្ថប្រយោជន៍នៃធនធានបរិស្ថានសំខាន់ៗដែលមាននៅក្នុងតំបន់គម្រោង។
- អប់រំពីវិធីសាស្ត្រជួយការពារបរិស្ថានក្នុង និងជុំវិញតំបន់គម្រោង។
- បំពាក់បំប៉នដល់បុគ្គលិក និងកម្មករក្នុងការគ្រប់គ្រងសំណល់រឹង-រាវ។
- អប់រំកម្មករឲ្យយល់ដឹងពីបញ្ហាជំងឺឆ្លងនានា ជាពិសេសវិធីការពារខ្លួនពីជំងឺគ្រុនចាញ់ និងជំងឺឆ្លងជាពិសេសការប្រុងប្រយ័ត្នចំពោះការប្រើប្រាស់គ្រឿងចក្រ។

៨.៥ កម្មវិធីត្រួតពិនិត្យបរិស្ថាន

នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសង្គមពេញលេញ តម្រូវឱ្យមានកម្មវិធីត្រួតពិនិត្យបរិស្ថាន (Environmental Monitoring Program) គឺជាកម្មវិធីមួយដែលម្ចាស់គម្រោងត្រូវធ្វើការត្រួតពិនិត្យដោយខ្លួនឯងនៃវដ្តជីវិតរបស់គម្រោង ដើម្បីចូលរួមកាត់បន្ថយនូវហេតុប៉ះពាល់ដែលអាចកើតមានឡើង ដើម្បីចូលរួមចំណែកការថែរក្សានូវបរិស្ថាន ក៏ដូចជាការអនុវត្តន៍នូវកិច្ចដំណើរការគម្រោងឱ្យមានស្ថេរភាព។ ដូចនេះការត្រួតពិនិត្យនេះ ម្ចាស់គម្រោងនឹងបញ្ជូនរបាយការណ៍ទៅឱ្យក្រសួងបរិស្ថានរៀងរាល់ ៣ ឆ្នាំម្តង។

កម្មវិធីត្រួតពិនិត្យបរិស្ថានត្រូវធ្វើឡើងនៅក្នុងដំណាក់កាលរបស់គម្រោងក្នុងនោះរួមមានដំណាក់កាលសាងសង់ ដំណាក់កាលប្រតិបត្តិគម្រោង និងដំណាក់ការប្រតិបត្តិគម្រោង។

៨.៥.១ ដំណាក់កាលរចនាគម្រោង

ក្នុងដំណាក់កាលនេះ ក្រុមការងារបច្ចេកទេសរបស់ក្រសួង និងមន្ទីរពាក់ព័ន្ធនឹងយកចិត្តទុកដាក់ទៅមូលហេតុ ទំហំផលប៉ះពាល់ និងតំបន់រងឥទ្ធិពល ដោយផលប៉ះពាល់ជាអវិជ្ជមានដោយសារការប្រើប្រាស់ឧបករណ៍សម្រាប់វិភាគលើសណ្ឌានដីបាតសមុទ្រលើដំបូង មុនឈានដល់ដំណាក់កាលបង្កប់ខ្សែកាប្ល៏។ លើសពីនេះ ក្រុមការងារបច្ចេកទេស នឹងត្រួតពិនិត្យហានិភ័យនានាដែលអាចមាននៅតំបន់ផ្ការថ្ម តំបន់នេសាទ ផ្លូវនាវាចរណ៍ តំបន់រុករកប្រេង និងឧស្ម័ន ជាដើម។ ផែនការគ្រប់គ្រងបរិស្ថាននៅក្នុងដំណាក់កាលនេះ នឹងលម្អិតនៅក្នុងដំណាក់ការប្រតិបត្តិគម្រោងនៃតារាង៨.៣។

៨.៥.២ ដំណាក់កាលសាងសង់

នៅក្នុងដំណាក់កាលនេះ ជាដំណាក់កាលមួយបង្កឱ្យមានហេតុប៉ះពាល់ដល់បញ្ហាបរិស្ថាន និងសង្គមជាអវិជ្ជមានក្នុងរយៈពេលខ្លី ដោយសកម្មភាពគម្រោងមួយចំនួនដែលបណ្តាលឱ្យមានការបំរែបំរួលសណ្ឌានដី ការហូរច្រោះ/បាក់ដី ប៉ះពាល់ដល់គុណភាពទឹក គុណភាពដី គុណភាពខ្យល់ សម្លេង និងរំញ័រ ជីវៈចំរុះក្នុងសមុទ្រ គ្រោះថ្នាក់នៅពេលជីកដាក់ខ្សែកាប្ល៏ និងការសាងសង់ស្ថានីយ៍ខ្សែកាប្ល៏ ប៉ះពាល់ដល់សោភ័ណ្ឌភាព ទេសចរណ៍ និងព្រមទាំងប៉ះពាល់ដល់សុខុមាលភាពសាធារណៈផងដែរ។

ផែនការគ្រប់គ្រងបរិស្ថាននៅក្នុងដំណាក់កាលនេះ នឹងត្រូវធ្វើឡើងដោយក្រសួង និងមន្ទីរស្ថាប័នពាក់ព័ន្ធ។ ពួកគេនឹងត្រួតពិនិត្យទៅលើមូលហេតុប៉ះពាល់ ទីតាំង និងទំហំនៃផលប៉ះពាល់បរិស្ថាន និងសង្គមដែលបង្កើតឡើងដោយសកម្មភាពគម្រោង។ ជាក់ស្តែងនៅក្នុងដំណាក់កាលនេះ សកម្មភាពឈូស

ឆាយ ជីកដាក់បង្កប់ខ្សែកាប្ល៍ និងការសាងសង់ អាចនឹងធ្វើឱ្យខូចសណ្ឋានដី និងការហូរច្រោះនៅតាមតំបន់ឆ្នេរជាដើម។ ដូច្នេះ ក្រសួងឬមន្ទីរបរិស្ថាន និងមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ មានតួនាទីត្រួតពិនិត្យលើកម្មភាពទាំងនេះ ដើម្បីកំណត់នូវហានិភ័យនានាដែលធ្វើឱ្យខូចសណ្ឋានដី និងធ្វើឱ្យមានការហូរច្រោះជាដើម។ ទន្ទឹមនឹងនេះ រាល់ការចំណាយ និងស្នាក់នៅក្នុងកំឡុងពេលត្រួតពិនិត្យរបស់ក្រសួង និងមន្ទីរទាំងពាក់ព័ន្ធទាំង ជាបន្ទុករបស់ម្ចាស់វិនិយោគទុន។ លម្អិតនៃផែនការគ្រប់គ្រងបរិស្ថាន ត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងតារាង៨.៣។

៨.៤.៣ ដំណាក់កាលប្រតិបត្តិគម្រោង

ក្នុងដំណាក់កាលនេះ ក្រុមការងារបច្ចេកទេសរបស់ក្រសួង និងមន្ទីរពាក់ព័ន្ធនឹងយកចិត្តទុកដាក់ទៅមូលហេតុ ទំហំផលប៉ះពាល់ និងតំបន់រងឥទ្ធិពល ដោយផលប៉ះពាល់ជាអវិជ្ជមានរបស់កម្លាំងមេកានិកដែលនឹងភាយចេញពីបណ្តាញខ្សែកាប្ល៍។ លើសពីនេះ ក្រុមការងារបច្ចេកទេស នឹងត្រួតពិនិត្យហានិភ័យនានាដូចជាការធ្វើកើនឡើងកម្តៅដែលអាចភាយចេញពីខ្សែ និងការដាច់ខ្សែនៅតាមតំបន់ឆ្នេរដែលអាចធ្វើឱ្យខូចសោភណ្ឌភាពដល់ឆ្នេរខ្សាច់ជាដើម។ ផែនការគ្រប់គ្រងបរិស្ថាននៅក្នុងដំណាក់កាលនេះ នឹងលម្អិតនៅក្នុងដំណាក់ការប្រតិបត្តិគម្រោងនៃតារាង៨.៣។

៨.៤.៤ ដំណាក់កាលបញ្ចប់គម្រោង

ផែនការតាមដាននិងត្រួតពិនិត្យបរិស្ថានក្នុងពេលបញ្ចប់គម្រោង គឺដើម្បីប្រមើមើលឱ្យឃើញថាហេតុប៉ះពាល់បរិស្ថានក្នុងដំណាក់កាលនេះ ត្រូវបានលុបបំបាត់ ឬកាត់បន្ថយមុនគម្រោង បញ្ឈប់ដំណើរការ។ ជាការពិតណាស់ ការត្រួតពិនិត្យនេះធ្វើការតាមដានទៅលើការអនុវត្តន៍ជាក់ស្តែងតាមវិធានការកាត់បន្ថយដែលចាំបាច់ត្រូវ៖

- លុបបំបាត់ ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានដល់ធនធានបរិស្ថាន និងស្ថានភាព សេដ្ឋកិច្ច-សង្គមដែលមាននៅក្នុងនិងជុំវិញទីតាំងគម្រោង។
- ជួសជុល ឬស្តារឡើងវិញនូវធនធានបរិស្ថាន និងរចនាសម្ព័ន្ធនៅជុំវិញ ដែលទទួលរងការខូចខាតដោយសារសកម្មភាពគម្រោង។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

តារាង៨.២៖ កម្មវិធីអង្កេតតាមដានបរិស្ថាន

បរិយាយ	ការត្រួតពិនិត្យ	ទីតាំង និងសកម្មភាពអង្កេតពិនិត្យ	ខួបនៃការត្រួតពិនិត្យ	អ្នកទទួលខុសត្រូវ	ស្ថាប័នត្រួតពិនិត្យ	ការប៉ាន់ប្រមាណតំលៃ (ដុល្លា)
១. ជំណាក់កាលរចនាគម្រោង						
តំបន់ផ្កាថ្ម	• សិក្សាស្ថានភាពបាតសមុទ្រ • សិក្សាជម្រៅទឹក • សិក្សាអំពីជម្រើសនៃគន្លងខ្សែកាប្លឹ	• តាមគន្លងនៃខ្សែកាប្លឹដែលបង្កប់ • ក្រោមបាតសមុទ្រ	មុនពេលសាងសង់ខ្សែកាប្លឹ	• ម្ចាស់គម្រោង • អ្នកមៅការគម្រោង	• ក្រសួងបរិស្ថាន • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	តាមស្ថានភាពជាក់ស្តែង
តំបន់នេសាទ	• សិក្សាស្ថានភាពបាតសមុទ្រ • សិក្សាជម្រៅទឹក • សិក្សាអំពីជម្រើសនៃគន្លងខ្សែកាប្លឹ	• តាមគន្លងនៃខ្សែកាប្លឹដែលបង្កប់ • ក្រោមបាតសមុទ្រ	មុនពេលសាងសង់ខ្សែកាប្លឹ	• ម្ចាស់គម្រោង • អ្នកមៅការគម្រោង	• ក្រសួងបរិស្ថាន • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	តាមស្ថានភាពជាក់ស្តែង
ផ្លូវនាវាចរណ៍	• សិក្សាស្ថានភាពបាតសមុទ្រ • សិក្សាជម្រៅទឹក • សិក្សាអំពីជម្រើសនៃគន្លងខ្សែកាប្លឹ	• តាមគន្លងនៃខ្សែកាប្លឹដែលបង្កប់ • ក្រោមបាតសមុទ្រ	មុនពេលសាងសង់ខ្សែកាប្លឹ	• ម្ចាស់គម្រោង • អ្នកមៅការគម្រោង	• ក្រសួងបរិស្ថាន • ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	តាមស្ថានភាពជាក់ស្តែង
តំបន់រុករកប្រេង និងឧស្ម័ន	• សិក្សាស្ថានភាពបាតសមុទ្រ • សិក្សាជម្រៅទឹក • សិក្សាអំពីជម្រើសនៃគន្លងខ្សែកាប្លឹ	• តាមគន្លងនៃខ្សែកាប្លឹដែលបង្កប់ • ក្រោមបាតសមុទ្រ	មុនពេលសាងសង់ខ្សែកាប្លឹ	• ម្ចាស់គម្រោង • អ្នកមៅការគម្រោង	• ក្រសួងបរិស្ថាន • ក្រសួងរ៉ែ និងថាមពល	តាមស្ថានភាពជាក់ស្តែង
តំបន់ឆ្នេរ និងផ្លូវ	• សាងសង់រ៉ែហ្គា	• ឆ្នេរអូរត្រេះ	មុនពេលសាង	• ម្ចាស់គម្រោង	• ក្រសួងបរិស្ថាន	តាមស្ថានភាព

បរិយាយ	ការត្រួតពិនិត្យ	ទីតាំង និងសកម្មភាពអង្កេតពិនិត្យ	ខួបនៃការត្រួតពិនិត្យ	អ្នកទទួល ខុសត្រូវ	ស្ថាប័នត្រួតពិនិត្យ	ការប៉ាន់ប្រមាណតំលៃ (ដុល្លា)
ស្របតំបន់ឆ្នេរ	• សាងសង់ប្រព័ន្ធការពារខ្សែកាប្ល៊ីនៅលើគោក និងតំបន់ឆ្នេរ	• ផ្លូវស្របឆ្នេរអូរត្រេះ	សង់ខ្សែកាប្ល៊ី	• អ្នកមៅការគម្រោង	• មន្ទីរសាធារណៈ និងដឹកជញ្ជូនខេត្តព្រះសីហនុ	ជាក់ស្តែង
២. ដំណាក់កាលសាងសង់						
២.១ ការបន្ថប់ខ្សែកាប្ល៊ីក្រោមបាតសមុទ្រ						
ក. ធនធានរូបសាស្ត្រ						
សណ្ឋានដីក្រោមបាតសមុទ្រ	• សកម្មភាពជីកដីក្រោមបាតសមុទ្រ • សកម្មភាពបង្កប់ខ្សែ	• តាមគន្លងនៃខ្សែកាប្ល៊ីដែលបង្កប់ • ក្រោមបាតសមុទ្រ	ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៊ី	• ម្ចាស់គម្រោង • អ្នកមៅការគម្រោង	• មន្ទីរទូរគមនាគមន៍ • ក្រសួងបរិស្ថាន	តាមស្ថានភាពជាក់ស្តែង
ភាពកកវណ្ណក់	• ទឹកសមុទ្រ • សកម្មភាពជីកបង្កប់ខ្សែកាប្ល៊ី	• ត្រួតពិនិត្យការចល័តកប៉ាល់ • ទំលាក់ម៉ាស៊ីន និងយុទ្ធភ្ជា • ជីកកកាយស្រទាប់ដីបាតសមុទ្រ	ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៊ី	• ម្ចាស់គម្រោង • អ្នកមៅការគម្រោង	• ក្រសួងបរិស្ថាន	តាមស្ថានភាពជាក់ស្តែង
គុណភាពខ្យល់	• ការបញ្ចេញផ្សែងពីកប៉ាល់ • ការបញ្ចេញផ្សែងពីម៉ាស៊ីន និងឧបករណ៍ផ្សេងៗ	• ត្រួតពិនិត្យម៉ាស៊ីនកប៉ាល់ • ម៉ាស៊ីន និងឧបករណ៍ផ្សេងៗ • ប្រេងប្រើប្រាស់សម្រាប់កប៉ាល់	ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៊ី	• ម្ចាស់គម្រោង • អ្នកមៅការគម្រោង	• ក្រសួងបរិស្ថាន • មន្ទីរប្រៃសនីយ៍ និងទូរគមនាគមន៍	តាមស្ថានភាពជាក់ស្តែង
ការរំខានដោយសំឡេង និងរំញ័រ	• សកម្មភាពបង្កប់ខ្សែកាប្ល៊ី • ការប្រើប្រាស់ម៉ាស៊ីនគ្រប់ប្រភេទ	• ត្រួតពិនិត្យលើទីតាំងទុកដាក់សំណល់រឹង និងរាវបណ្តោះអសន្ន របស់គម្រោង	ត្រួតពិនិត្យជាប្រចាំពេលបង្កប់	• ម្ចាស់គម្រោង • អ្នកមៅការគម្រោង	• ក្រសួងបរិស្ថាន • មន្ទីរប្រៃសនីយ៍ និងទូរគមនាគមន៍	តាមស្ថានភាពជាក់ស្តែង

បរិយាយ	ការត្រួតពិនិត្យ	ទីតាំង និងសកម្មភាពអង្កេតពិនិត្យ	ខួបនៃការត្រួតពិនិត្យ	អ្នកទទួលខុសត្រូវ	ស្ថាប័នត្រួតពិនិត្យ	ការប៉ាន់ប្រមាណតំលៃ (ដុល្លា)
			ខ្សែកាប្ល៊ី			
គុណភាពទឹក	• ការបញ្ចេញសំណល់រឹង-រាវ	• ការទុកដាក់សំណល់រឹង-រាវនៅលើកប៉ាល់	ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៊ី	• ម្ចាស់គម្រោង • អ្នកមៅការគម្រោង	• ក្រសួងបរិស្ថាន • មន្ទីរប្រៃសនីយ៍ និងទូរគមនាគមន៍	តាមស្ថានភាពជាក់ស្តែង
ខ. ធនធានជីវសាស្ត្រ						
ធនធានសមុទ្រ	• សកម្មភាពអូសម៉ាស៊ីនដើម្បីបង្កប់ខ្សែកាប្ល៊ី • ការប្រើប្រាស់ប្រេងឥន្ធនៈ • ការបញ្ចេញសំណង់រឹង-រាវនៅលើកប៉ាល់	• ពិនិត្យលើសកម្មភាពជីកបង្កប់ខ្សែ • ការទុកដាក់ប្រេងឥន្ធនៈសម្រាប់ម៉ាស៊ីនគ្រប់ប្រភេទ • ការគ្រប់គ្រងសំណល់រឹង-រាវ • គុណភាពទឹក	• ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៊ី • រាល់ពេលប្រើប្រាស់ឥន្ធនៈ	• ម្ចាស់គម្រោង • អ្នកមៅការគម្រោង	• ក្រសួងបរិស្ថាន • រដ្ឋបាលជលផល	តាមស្ថានភាពជាក់ស្តែង
គ. ធនធានសង្គម-សេដ្ឋកិច្ច						
ប្រជានេសាទ	• សកម្មភាពបង្កប់ខ្សែកាប្ល៊ី • សកម្មភាពនេសាទរបស់ប្រជាជន	• ពិនិត្យលើសកម្មភាពជីកបង្កប់ខ្សែ • មតិយោបល់របស់ប្រជានេសាទ • ធនធានជលផល • គុណភាពទឹក	• ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៊ី	• ម្ចាស់គម្រោង • អ្នកមៅការ	• ក្រសួងបរិស្ថាន • រដ្ឋបាលជលផល	តាមស្ថានភាពជាក់ស្តែង
នាវាចរណ៍	• សកម្មភាពបង្កប់ខ្សែកាប្ល៊ី • សកម្មភាពរបស់កប៉ាល់ដឹកទំនិញ ទូកទេសចរណ៍ និង	• ពិនិត្យលើសកម្មភាពជីកបង្កប់ខ្សែ • ទូកនាវាចរណ៍ • ធនធានជលផល	• ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៊ី	• ម្ចាស់គម្រោង • អ្នកមៅការ	• ក្រសួងបរិស្ថាន • ក្រសួងទេចរណ៍ • ក្រសួងកសិកម្ម	តាមស្ថានភាពជាក់ស្តែង

បរិយាយ	ការត្រួតពិនិត្យ	ទីតាំង និងសកម្មភាពអង្កេតពិនិត្យ	ខួបនៃការត្រួតពិនិត្យ	អ្នកទទួលខុសត្រូវ	ស្ថាប័នត្រួតពិនិត្យ	ការប៉ាន់ប្រមាណតំលៃ (ដុល្លា)
	ទូកនេសាទ	• គុណភាពទឹក			រុក្ខាប្រមាញ់ និងនេសាទ	
សុខភាព និងសុវត្ថិភាពការងារ	• ការបញ្ចេញសំណង់រឹង-រាវនៅលើកប៉ាល់ • សុវត្ថិភាពការងារ • ការអិលធ្លាក់ • ការលង់ទឹក	• ត្រួតពិនិត្យមើលទីតាំងទុកដាក់សំណល់រឹង-រាវ • ពិនិត្យមើលអនាម័យនៃការរស់នៅរបស់កម្មករ និងបុគ្គលិក • ការប្រើប្រាស់សម្ភារៈ: សំលៀកបំពាក់ ស្បែកជើង និងឧបករណ៍ការពារ	ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៊ី	• ម្ចាស់គម្រោង • អ្នកមៅការ	• ក្រសួងបរិស្ថាន • មន្ទីរបរិស្ថាន • មន្ទីរការងារ បណ្តោះបណ្តាលវិជ្ជាជីវ និងយុវសម្បទ្ធា	តាមស្ថានភាពជាក់ស្តែង
តំបន់ប្តូកប្រេង	• ការបង្កប់ខ្សែកាប្ល៊ីក្រោមបាតសមុទ្រ	• ពិនិត្យមើលសកម្មភាពជីកបង្កប់ខ្សែកាប្ល៊ី • ពិនិត្យតំបន់ប្តូកប្រេង និងឧស្ម័ននីមួយៗដែលគន្លងខ្សែកាប្ល៊ីឆ្លងកាត់	• ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៊ី • ពេលប្រតិបត្តិគម្រោង	• ម្ចាស់គម្រោង • អ្នកមៅការ	• ក្រសួងបរិស្ថាន • មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍	តាមស្ថានភាពជាក់ស្តែង
២.២ ដំណើរការបង្ហប់ខ្សែកាប្ល៊ីនៅលើដីគោក						
ក. ធនធានរូបសាស្ត្រ						
សណ្ឋានដី	• ការឈូសឆាយដី • ការពង្រាបដីឡើងវិញ	• ផ្ទៃអូរត្រេះ • សួនច្បារផ្ទៃអូរត្រេះ • ផ្លូវ	• ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៊ី	• ម្ចាស់គម្រោង • អ្នកមៅការ	• ក្រសួងបរិស្ថាន • សាលាខេត្តព្រះសីហនុ	តាមស្ថានភាពជាក់ស្តែង

បរិយាយ	ការត្រួតពិនិត្យ	ទីតាំង និងសកម្មភាពអង្កេតពិនិត្យ	ខួបនៃការត្រួតពិនិត្យ	អ្នកទទួលខុសត្រូវ	ស្ថាប័នត្រួតពិនិត្យ	ការប៉ាន់ប្រមាណតំលៃ (ដុល្លា)
					• មន្ទីរសាធារណៈ និងដឹកជញ្ជូនខេត្តព្រះសីហនុ	
ការហូរច្រោះដី/ ការខូចគុណភាពដី	• ការឈូសឆាយដី • សង់ស្ថានីយ៍ខ្សែកាប្ល៍ • ការប្រើប្រាស់គ្រឿងចក្រ	• ទីតាំងសាងសង់រ៉ែហ្គា • ទីតាំងសាងសង់ស្ថានីយ៍ខ្សែកាប្ល៍	• ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៍	• ម្ចាស់គម្រោង • អ្នកមៅការ	• ក្រសួងបរិស្ថាន • សាលាខេត្តព្រះសីហនុ • មន្ទីរសាធារណៈ និងដឹកជញ្ជូនខេត្តព្រះសីហនុ	តាមស្ថានភាពជាក់ស្តែង
ការរំខានដោយសំឡេង និងរំញ័រ	• ការឈូសឆាយដី • សង់ស្ថានីយ៍ខ្សែកាប្ល៍ • ការប្រើប្រាស់គ្រឿងចក្រ	• ទីតាំងសាងសង់រ៉ែហ្គា • ទីតាំងសាងសង់ស្ថានីយ៍ខ្សែកាប្ល៍	• ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៍	• ម្ចាស់គម្រោង • អ្នកមៅការ	• ក្រសួងបរិស្ថាន • សាលាខេត្តព្រះសីហនុ • មន្ទីរសាធារណៈ និងដឹកជញ្ជូនខេត្តព្រះសីហនុ	តាមស្ថានភាពជាក់ស្តែង
គុណភាពខ្យល់	• ការឈូសឆាយដី • សង់ស្ថានីយ៍ខ្សែកាប្ល៍ • ការប្រើប្រាស់គ្រឿងចក្រ	• ទីតាំងសាងសង់រ៉ែហ្គា • ទីតាំងសាងសង់ស្ថានីយ៍ខ្សែកាប្ល៍	• ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៍	• ម្ចាស់គម្រោង • អ្នកមៅការ	• ក្រសួងបរិស្ថាន • សាលាខេត្តព្រះសីហនុ • មន្ទីរសាធារណៈ	តាមស្ថានភាពជាក់ស្តែង

Draft

បរិយាយ	ការត្រួតពិនិត្យ	ទីតាំង និងសកម្មភាពអង្កេតពិនិត្យ	ខួបនៃការត្រួតពិនិត្យ	អ្នកទទួលខុសត្រូវ	ស្ថាប័នត្រួតពិនិត្យ	ការប្រាន់ប្រមាណតំលៃ (ដុល្លា)
					និងដឹកជញ្ជូនខេត្ត ព្រះសីហនុ	
គុណភាពទឹក	• ករកាយដី • ការគ្រប់គ្រងសំណល់រឹង-រាវ	• ទីតាំងសាងសង់រ៉ូហ្គា • ទីតាំងសាងសង់ស្ថានីយ៍ខ្សែកាប្ល៉ូ	• ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៉ូ	• ម្ចាស់គម្រោង • អ្នកមៅការ	• ក្រសួងបរិស្ថាន • សាលាខេត្តព្រះសីហនុ • មន្ទីរសាធារណៈ និងដឹកជញ្ជូនខេត្ត ព្រះសីហនុ	តាមស្ថានភាពជាក់ស្តែង
ខ. ស្ថានភាពសង្គម-សេដ្ឋកិច្ច						
ការប៉ះពាល់ដល់របរប្រជាជន	• ការឈូសឆាយដី • ការបង្កប់ខ្សែកាប្ល៉ូនៅលើដីគោក	• ទីតាំងសាងសង់រ៉ូហ្គា • ទីតាំងសាងសង់ស្ថានីយ៍ខ្សែកាប្ល៉ូ	• ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៉ូ	• ម្ចាស់គម្រោង • អ្នកមៅការ	• ក្រសួងបរិស្ថាន • សាលាខេត្តព្រះសីហនុ • មន្ទីរសាធារណៈ និងដឹកជញ្ជូនខេត្ត ព្រះសីហនុ	តាមស្ថានភាពជាក់ស្តែង
សុខភាពសាធារណៈ	• ការឈូសឆាយដី • ការបង្កប់ខ្សែកាប្ល៉ូនៅលើដីគោក	• ទីតាំងសាងសង់រ៉ូហ្គា • ទីតាំងសាងសង់ស្ថានីយ៍ខ្សែកាប្ល៉ូ	• ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៉ូ	• ម្ចាស់គម្រោង • អ្នកមៅការ	• ក្រសួងបរិស្ថាន • មន្ទីរសុខាភិបាលខេត្តព្រះសីហនុ	តាមស្ថានភាពជាក់ស្តែង
សោភ័ណភាព/	• សាងសង់រ៉ូហ្គា	• ទីតាំងសាងសង់រ៉ូហ្គា	• ត្រួតពិនិត្យជា	• ម្ចាស់គម្រោង	• ក្រសួងបរិស្ថាន	តាមស្ថានភាព

Draft

បរិយាយ	ការត្រួតពិនិត្យ	ទីតាំង និងសកម្មភាពអង្កេតពិនិត្យ	ខួបនៃការត្រួតពិនិត្យ	អ្នកទទួលខុសត្រូវ	ស្ថាប័នត្រួតពិនិត្យ	ការប៉ាន់ប្រមាណតំលៃ (ដុល្លា)
ទេសភាព	• សាងសង់ស្ពានីយ៍	• ទីតាំងសាងសង់ស្ពានីយ៍ខ្សែកាប្ល៊	ប្រចាំពេលបង្កប់ខ្សែកាប្ល៊	• អ្នកមៅការ	• មន្ទីរសាធារណៈ និងដឹកជញ្ជូនខេត្ត ព្រះសីហនុ	ជាក់ស្តែង
តំបន់វប្បធម៌/តំបន់បេតិកភ័ណ្ឌ	• សាងសង់រ៉ែហ្គា • សាងសង់ស្ពានីយ៍	• ទីតាំងសាងសង់រ៉ែហ្គា • ទីតាំងសាងសង់ស្ពានីយ៍ខ្សែកាប្ល៊	• ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៊	• ម្ចាស់គម្រោង • អ្នកមៅការ	• ក្រសួងបរិស្ថាន • មន្ទីរសុខាភិបាលខេត្តព្រះសីហនុ	តាមស្ថានភាពជាក់ស្តែង
ចរាចរណ៍	• សាងសង់រ៉ែហ្គា • សាងសង់ស្ពានីយ៍	• ទីតាំងសាងសង់រ៉ែហ្គា • ទីតាំងសាងសង់ស្ពានីយ៍ខ្សែកាប្ល៊	• ត្រួតពិនិត្យជាប្រចាំពេលបង្កប់ខ្សែកាប្ល៊	• ម្ចាស់គម្រោង • អ្នកមៅការ	• ក្រសួងបរិស្ថាន • មន្ទីរសាធារណៈ និងដឹកជញ្ជូនខេត្ត ព្រះសីហនុ	តាមស្ថានភាពជាក់ស្តែង
៣. ដំណាក់កាលប្រតិបត្តិគម្រោង						
៣.១ ធនធានរូបសាស្ត្រ						
ស្រទាប់ដីក្រោមបាតសមុទ្រ	• ខ្សែកាប្ល៊ដែលបង្កប់ • សណ្ឋានភាពខ្សែកាប្ល៊	• ទីតាំងបង្កប់ខ្សែកាប • វាស់កម្រិតសីតុណ្ហភាព នៅតំបន់ជុំវិញកន្លែងបង្កប់ខ្សែកាប្ល៊	• ៣ ខែម្តង	• ម្ចាស់គម្រោង	• ក្រសួងបរិស្ថាន • មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍	តាមស្ថានភាពជាក់ស្តែង
ការលេចឡើងខ្សែកាប្ល៊	• សណ្ឋានភាពខ្សែកាប្ល៊	• តំបន់ឆ្នេរ • ទីតាងដែលមានសំណឹកខ្លាំង	• ៣ ខែម្តង	• ម្ចាស់គម្រោង	• ក្រសួងបរិស្ថាន • មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍	តាមស្ថានភាពជាក់ស្តែង

Draft

បរិយាយ	ការត្រួតពិនិត្យ	ទីតាំង និងសកម្មភាពអង្កេតពិនិត្យ	ខួបនៃការត្រួតពិនិត្យ	អ្នកទទួលខុសត្រូវ	ស្ថាប័នត្រួតពិនិត្យ	ការប៉ាន់ប្រមាណតំលៃ (ដុល្លា)
៣.២ ធនធានជីវសាស្ត្រ						
ធនធានសមុទ្រ	• ការដាច់ខ្សែកាប • សណ្ឋានភាពខ្សែកាប្ល៊ី	• ទីតាំងខ្សែកាប្ល៊ីដែលបានបង្កប់ទាំងអស់	• ៣ ខែម្តង	• ម្ចាស់គម្រោង	• ក្រសួងបរិស្ថាន • មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍	តាមស្ថានភាពជាក់ស្តែង
៤. ដំណាក់កាលបញ្ចប់គម្រោង						
ការរក្សាទុកខ្សែកាប្ល៊ីក្រោមបាតសមុទ្រ	• ការរក្សាទុកខ្សែកាប្ល៊ីក្រោមបាតសមុទ្រ	• ទីតាំងបង្កប់ខ្សែកាប្ល៊ី	• មួយដងនៅពេលបញ្ចប់គម្រោង	• ម្ចាស់គម្រោង • អ្នកមៅការ	• ក្រសួងបរិស្ថាន • ក្រសួងប្រៃសណីយ៍និទ្ទេសមនាគមន៍	តាមស្ថានភាពជាក់ស្តែង

កំណត់សម្គាល់៖ តំណាងក្រសួងបរិស្ថាន និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នឹងប្រចាំការនៅលើកប៉ាល់នៅក្នុងដំណាក់កាលសាងសង់ ដឹកកប់ខ្សែកាប្ល៊ីនៅក្រោមបាតសមុទ្រ ហើយរាល់ការចំណាយជាបន្ទុករបស់ក្រុមហ៊ុនម្ចាស់គម្រោង ព្រមទាំងផ្តល់លិខិតធានារ៉ាប់រងដល់អាយុជីវិតរបស់មន្ត្រីរាជការដែលបម្រើការងារប្រចាំនៅលើកប៉ាល់។

Draft

៨.៦ មូលនិធិបរិស្ថាន និងសង្គម

ដើម្បីឆ្លើយតបទៅនឹងគោលការណែនាំរបស់ក្រសួងបរិស្ថាន ក៏ដូចជាការរួមចំណែកក្នុងការស្តារ និងធ្វើឱ្យបរិស្ថានធម្មជាតិ និងសង្គមមានភាពប្រសើរឡើង ក្រុមហ៊ុនវិនិយោគ នឹងមានកញ្ចប់មូលនិធិសម្រាប់ជួយផ្នែកសំខាន់ទាំង២នេះ ចំនួន៣០.០០០ដុល្លាក្នុងមួយឆ្នាំសម្រាប់រយៈពេល១០ឆ្នាំ បន្ទាប់ពីគម្រោងចាប់ដំណើរការ។ ផែនការមូលនិធិសម្រាប់បរិស្ថានមានចំនួន ១០០.០០០ដុល្លារ ក្នុងរយៈពេល១០ឆ្នាំ ដោយក្នុងមួយឆ្នាំ ក្រុមហ៊ុននឹងចំណាយ១០.០០០ដុល្លា ទៅលើសកម្មភាពអភិរក្ស ធនធានជីវៈចម្រុះក្នុងសមុទ្រ។ ចំណែកឯ កញ្ចប់មូលនិធិសម្រាប់សង្គមវិញ ក្រុមហ៊ុននឹងចំណាយអស់ថវិការ ២០០.០០០ដុល្លារក្នុងរយៈពេល១០ឆ្នាំ ដោយផ្តោតទៅលើសកម្មភាពចំនួន២ គឺ (១) សកម្មភាពសម្អាតតំបន់ឆ្នេរដែលនឹងត្រូវចំណាយ៦.០០០ដុល្លារ ក្នុងមួយឆ្នាំ និង(២)សាងសង់ហេដ្ឋារចនាសម្ព័ន្ធត្រូវចំណាយថវិការ១៤.០០០ដុល្លារក្នុងមួយឆ្នាំ។

Draft

តារាង៨.៣៖ មូលនិធិបរិស្ថាន និងសង្គមសម្រាប់គម្រោងបង្កប់ខ្សែកាប្ល៊ីអុបទិច

ល.រ	សកម្មភាព	ឆ្នាំទី១	ឆ្នាំទី២	ឆ្នាំទី៣	ឆ្នាំទី៤	ឆ្នាំទី៥	ឆ្នាំទី៦	ឆ្នាំទី៧	ឆ្នាំទី៨	ឆ្នាំទី៩	ឆ្នាំទី១០	សរុប (USD)
ក.	មូលនិធិបរិស្ថាន											១០០.០០០
១	អភិរក្សជីវៈចម្រុះក្នុងសមុទ្រ	១០.០០០	១០.០០០	១០.០០០	១០.០០០	១០.០០០	១០.០០០	១០.០០០	១០.០០០	១០.០០០	១០.០០០	១០០.០០០
ខ.	មូលនិធិសង្គម											២០០.០០០
២	សកម្មភាពសម្អាតឆ្នេរ	៦.០០០	៦.០០០	៦.០០០	៦.០០០	៦.០០០	៦.០០០	៦.០០០	៦.០០០	៦.០០០	៦.០០០	៦០.០០០
៣	សាងសង់ហេដ្ឋារចនាសម្ព័ន្ធ	១៥.០០០	១៥.០០០	១៥.០០០	១៥.០០០	១៥.០០០	១៥.០០០	១៥.០០០	១៥.០០០	១៥.០០០	១៥.០០០	១៥០.០០០
សរុប		៣០.០០០	៣០.០០០	៣០.០០០	៣០.០០០	៣០.០០០	៣០.០០០	៣០.០០០	៣០.០០០	៣០.០០០	៣០.០០០	**៣០០.០០០**

កំណត់សម្គាល់៖ មូលនិធិនេះមានរយៈពេល១០ឆ្នាំម្តងនៅក្នុងវដ្តនៃគម្រោង ហើយមូលនិធិនេះមានការប្រែប្រួល បន្ទាប់ពីលិខិតបទដ្ឋានគតិយុត្តចូលជាធរមាន។

Draft